ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៦៣ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិ សំរបសំរួលបរិស្ថានតំបន់ឆ្នេរសមុទ្រ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតនិងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ-បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

# សំរេច

**ប្រការ ១.-**

បង្កើតគណៈកម្មាធិការជាតិសំរបសំរួលបរិស្ថានតំបន់ឆ្នេរសមុទ្រ ដែលហៅថា **គ.ជ.ស.ឆ** ដើម្បីសំរបសំរួលការងារគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ ការពារបរិស្ថាន និងធនធានធម្មជាតិនៅតំបន់ឆ្នេរសមុទ្រ ក្នុងទិសដៅលើកកំពស់ការជីវភាពរបស់ប្រជាជនដែលរស់នៅក្នុងតំបន់ឆ្នេរសមុទ្រ តាមរយៈការប្រើប្រាស់ និងការអភិវឌ្ឍន៏តំបន់ឆ្នេរប្រកបដោយនិរន្តរភាពនៅកម្ពុជា ។

**ប្រការ ២.-**

តំបន់ឆ្នេរសមុទ្ររួមមាន : ខេត្តកំពត ខេត្តកោះកុង ក្រុងព្រះសីហនុ និងក្រុងកែប ដោយរួមបញ្ចូលបូរណភាពដែនសមុទ្រ ដែលលាតសន្ធឹងដល់ព្រំដែនតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៣.-**

**គ.ជ.ស.ឆ** មានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១ - | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | ប្រធាន |
| ២ - | រដ្ឋលេខាធិការក្រសួងបរិស្ថាន | ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៣ - | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប | អនុប្រធាន |
| ៤ - | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១រូប | អនុប្រធាន |
| ៥ - | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| ៦ - | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៏ជនបទ | ១រូប | សមាជិក |
| ៧ - | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ១រូប | សមាជិក |
| ៨ - | អនុរដ្ឋលេខាធិការក្រសួងផែនការ | ១រូប | សមាជិក |
| ៩ - | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ១រូប | សមាជិក |
| ១០- | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ១រូប | សមាជិក |
| ១១ - | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ១រូប | សមាជិក |
| ១២ - | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | សមាជិក |
| ១៣ - | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | ១រូប | សមាជិក |

| | | | |
|---|---|---|---|
| ១៤ - | អគ្គលេខាធិការអាជ្ញាធរជាតិប្រេងកាត | | សមាជិក |
| ១៥ - | អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១រូប | សមាជិក |
| ១៦ - | អភិបាលខេត្តកំពត | | សមាជិក |
| ១៧- | ប្រតិភូរាជរដ្ឋាភិបាលក្រុងកែប | | សមាជិក |
| ១៨ - | អភិបាលក្រុងព្រះសីហនុ | | សមាជិក |
| ១៩ - | អភិបាលខេត្តកោះកុង | | សមាជិក |

**ប្រការ ៤.-**

**គ.ជ.ស.ឆ** មានតួនាទី និងភារៈកិច្ចដូចខាងក្រោម :

- សំរបសំរួលជាមួយស្ថាប័នជាតិ តំបន់ និងអ្នកផ្តល់ជំនួយ ដើម្បីដោះស្រាយបញ្ហាផ្សេងៗនៅតំបន់ឆ្នេរសមុទ្រ
- ពិនិត្យ និងផ្តល់យោបល់ជូនស្ថាប័នរាជរដ្ឋាភិបាល ដោយតំរង់ទិសគោលនយោបាយ ផែនការ ក្របខ័ណ្ឌច្បាប់ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ អោយស្របទៅនឹងអាទិភាពអភិវឌ្ឍន៍ជាតិ អនុសញ្ញា និងច្បាប់អន្តរ ជាតិផ្សេងៗ ដែលទាក់ទងក្នុងការគ្រប់គ្រងតំបន់ឆ្នេរ
- រៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាព និងលទ្ធផល ព្រមទាំងផ្តល់យោបល់ជាអនុសាសន៍ទានា ដើម្បីផ្ញើជូនរាជរដ្ឋាភិបាល
- ផ្តល់យោបល់ និងណែនាំដល់ការអនុវត្តន៍គ្រប់គំរោងតំបន់ឆ្នេរសមុទ្រ
- ស្វែងរកជំនួយបច្ចេកទេស និងថវិកា សំរាប់ទ្រទ្រង់ដល់ដំណើរការរបស់ **គ.ជ.ស.ឆ**
- ទទួលភារៈកិច្ចផ្សេងៗទៀតតាមសំណូមពររបស់រាជរដ្ឋាភិបាល ។

**ប្រការ ៥.-**

**គ.ជ.ស.ឆ** ប្រើប្រាស់ផ្នែកសំរបសំរួលតំបន់ឆ្នេរសមុទ្រនៃក្រសួងបរិស្ថាន ជាលេខាធិការដ្ឋានដែលមានទីតាំងនៅក្នុងក្រសួងបរិស្ថាន និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ។

**គ.ជ.ស.ឆ** អាចបង្កើតក្រុមបច្ចេកទេសជាតិ ដែលមានសមាសភាពជាមន្ត្រីមានក្របខ័ណ្ឌរដ្ឋ ជាជំនួយការដើម្បីអនុវត្តតាមតំរូវការ ភារៈកិច្ច ដូចមានចែងក្នុងមាត្រា ៤ នៃសេចក្តីសំរេចនេះ ។

**គ.ជ.ស.ឆ** អាចមានទីប្រឹក្សាជាតិ និងអន្តរជាតិមួយចំនួន ដែលមានសមាសភាពជាអ្នកជំនាញ ដើម្បីជួយទ្រទ្រង់លេខាធិការដ្ឋាន ។

**ប្រការ ៦.-**

- **គ.ជ.ស.ឆ** ត្រូវជួបប្រជុំយ៉ាងតិចម្តងក្នុងមួយត្រីមាស តាមការអញ្ជើញរបស់ប្រធាន
- សមាជិកណាដែលមិនអាចមកចូលរួមប្រជុំបាន អាចចាត់តាំងតំណាងអោយចូលរួមប្រជុំជំនួសបាន ។

**ប្រការ ៧.-**

លេខាធិការដ្ឋានរបស់ **គ.ជ.ស.ឆ** ត្រូវបំពេញភារៈកិច្ចតាមការកំណត់របស់ **គ.ជ.ស.ឆ** ។ លេខាធិការដ្ឋានដឹកនាំដោយលេខាធិការមួយរូប និងបុគ្គលិកមានស្រាប់របស់ផ្នែកសំរបសំរួលតំបន់ឆ្នេរសមុទ្រនៃក្រសួងបរិស្ថាន ។

**ប្រការ ៨.-**

គ.ជ.ស.ឆ ត្រូវបង្កើតក្រុមការងារខេត្ត-ក្រុង ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១ - | អភិបាលខេត្ត-ក្រុង | ប្រធាន |
| ២ - | ប្រធានមន្ទីរបរិស្ថាន | អនុប្រធានអចិន្ត្រៃយ៍ |
| ៣ - | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | អនុប្រធាន |
| ៤ - | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៥ - | ប្រធានមន្ទីរទេសចរណ៍ | សមាជិក |
| ៦ - | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៧ - | ប្រធានមន្ទីរកិច្ចការនារី និងអតីតយុទ្ធជន | សមាជិក |
| ៨ - | ប្រធានមន្ទីរផែនការ | សមាជិក |
| ៩ - | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០ - | ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១១ - | ប្រធានមន្ទីរធនធានទឹក និងឧតុនិយម | សមាជិក |
| ១២ - | ប្រធានស្នងការនគរបាល | សមាជិក |
| ១៣ - | មេបញ្ជាការកងរាជអាវុធហត្ថ | សមាជិក |
| ១៤ - | មេបញ្ជាការកងនាវាចរប្រចាំខេត្ត-ក្រុង | សមាជិក |

**ប្រការ ៩.-**

ក្រុមការងារខេត្ត-ក្រុង មានតួនាទី និងភារៈកិច្ចដូចខាងក្រោម :

- រៀបចំសកម្មភាពអាទិភាព ដើម្បីគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរសមុទ្រ នៅក្នុងខេត្ត-ក្រុង
- សំរបសំរួល គ្រប់ការអនុវត្តន៏គំរោងនៅខេត្ត-ក្រុងតំបន់ឆ្នេរ និងមន្ទីរ ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហានៅ តំបន់ឆ្នេរសមុទ្រ
- ផ្តល់យោបល់ជូន **គ.ជ.ស.ឆ** តាមរយៈប្រធានក្រុមការងារខេត្ត-ក្រុង អំពីបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រ
- ក្នុងករណីចាំបាច់ អាចបង្កើតក្រុមបច្ចេកទេសធ្វើផែនការ និងអនុវត្តសកម្មភាពផ្សេងៗជាមួយគំរោងតំបន់ឆ្នេរដែលសមាសភាពនៃក្រុមបច្ចេកទេសអាចរួមមាន : បុគ្គលិកដែលមកពីមន្ទីរផ្សេងៗក្នុងខេត្ត ស្រុក ឃុំ និង ភូមិ រួមបញ្ចូលទាំងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងតំណាងមួយចំនួនមកពីសហគមន៏មូលដ្ឋាន និងអ្នកពាក់ព័ន្ធ ដទៃៗទៀត
- ទទួលភារៈកិច្ចផ្សេងៗទៀត ដែល **គ.ជ.ស.ឆ** ប្រគល់អោយ ។

**ប្រការ ១០.-**

ក្រុមការងារខេត្ត-ក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់អាជ្ញាធរខេត្ត-ក្រុង ។

**ប្រការ ១១.-**

មន្ទីរបរិស្ថានខេត្ត-ក្រុង មានតួនាទីជាលេខាធិការដ្ឋាន និងបំពេញភារៈកិច្ចតាមការកំណត់របស់ខេត្ត-ក្រុង ។ លេខាធិការដ្ឋានខេត្ត-ក្រុង ត្រូវដឹកនាំដោយលេខាធិការមួយរូប ។

**ប្រការ ១២.-**

- ក្រុមការងារខេត្ត-ក្រុង ត្រូវជួបប្រជុំរៀងរាល់ខែ តាមការអញ្ជើញរបស់ប្រធាន
- សមាជិកណាដែលមិនអាចមកចូលរួមប្រជុំបាន អាចចាត់តាំងតំណាងអោយចូលរួមប្រជុំជំនួសបាន ។

**ប្រការ ១៣.-**

- អង្គការមិនមែនរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ ដែលមានគំរោងកម្មវិធីពាក់ព័ន្ធទៅនឹងតំបន់ឆ្នេរសមុទ្រ អាចចូលរួមប្រជុំក្នុង **គ.ជ.ស.ឆ** និងក្រុមការងារខេត្ត-ក្រុង ក្នុងនាមជាអ្នកសង្កេតការណ៏ ។

- លេខាធិការដ្ឋានរបស់ **គ.ជ.ស.ន** និងក្រុមការងារខេត្ត-ក្រុងនីមួយៗ ត្រូវជូនដំណឹងដល់អ្នកសង្កេតការណ៍ អំពីពេលវេលា និងទីកន្លែងប្រជុំរបស់សមាជិក **គ.ជ.ស.ន** ឬក្រុមការងារ ខេត្ត-ក្រុង ។
- អ្នកសង្កេតការណ៍មានសិទ្ធិចូលរួមប្រជុំ ប៉ុន្តែមិនអាចចូលរួមជាសមាជិកបានឡើយ ។
- ប្រធាន **គ.ជ.ស.ន** ឬក្រុមការងារខេត្ត-ក្រុង ដោយគំនិតផ្តួចផ្តើមខ្លួនផ្ទាល់ ឬក៏តាមសំណូមពររបស់សមាជិកអាចសុំជាគំនិតយោបល់ និងទស្សនៈរបស់អ្នកសង្កេតការណ៍ ទៅលើប្រធានបទដែលកំពុងពិភាក្សានៅក្នុងពេលប្រជុំ ។

**ប្រការ ១៤.–**

- ប្រធាន **គ.ជ.ស.ន** និងប្រធានក្រុមការងារខេត្ត-ក្រុង ត្រូវតាក់តែងរបៀបវារៈសំរាប់កិច្ចប្រជុំ និងដឹកនាំកិច្ចប្រជុំ ។

**ប្រការ ១៥.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ខេត្ត-ក្រុងដែលពាក់ព័ន្ធនឹងសេចក្តីសំរេចនេះ ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល:</u>

ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

ដូចប្រការ ១៥

ឯកសារ- កាលប្បវត្តិ